ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ និង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ......០១៤............ ស.ណ.ន

# សេចក្តីណែនាំរួម

## ស្តីពី

## ការលើកស្លាកសញ្ញាគណបក្សនយោបាយ និងការបិទផ្សាយសម្ភារៈឯកសារ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីគណបក្សនយោបាយ
- យោងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ជំពូកទី ៧ ស្តីពីការឃោសនាបោះឆ្នោត
- យោងសេចក្តីជូនដំណឹងលេខ ៥៧៧ ស.ណ.ន របស់ក្រសួងមហាផ្ទៃចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ។

ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមណែនាំដល់អាជ្ញាធរដែនដី និងគណៈកម្មការរៀបចំការបោះឆ្នោតនៅគ្រប់លំដាប់ថ្នាក់ ឱ្យសហការចាត់ចែងអនុវត្តក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត តាមខ្លឹមសារណែនាំដូចខាងក្រោម :

១- ការលើកស្លាកគណបក្សនយោបាយជាអចិន្ត្រៃយ៍ និងការលើកស្លាកគណបក្សនយោបាយបំរើគោលដៅឃោសនាបោះឆ្នោត ក្នុងអំឡុងពេលឃោសនាបោះឆ្នោត និងការបិទផ្សាយសម្ភារៈឯកសារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត នៅទីស្នាក់ការរបស់ខ្លួន ឬលំនៅដ្ឋានឯកជន ឬទីកន្លែងឯកជន ត្រូវមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិទាំងនោះ ។ ក្នុងករណីនេះ គណបក្សនយោបាយសាមីគ្រាន់តែជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរឃុំ សង្កាត់ ដោយមិនតម្រូវឱ្យមានការសុំច្បាប់អនុញ្ញាតជាមុនពីអាជ្ញាធរទេ ។

២- ការលើកស្លាកគណបក្សនយោបាយជាអចិន្ត្រៃយ៍នៅតាមទីសាធារណៈ ត្រូវអនុវត្តតាមសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃលេខ ៥៧៧ ស.ណ.ន ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ។